**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១០៤៦/២០ ក.អ.ជ

ថ្ងៃព្រហស្បតិ៍ ១០កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០២០

# របាយការណ៍
# វឌ្ឍនភាពការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២០
# របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## ១.សេចក្តីផ្តើម

គិតរហូតដល់ចុងឆមាសទី១ ដើមឆ្នាំ២០២០ ជម្ងឺកូវីដ១៩ នៅតែបន្តការរាតត្បាតកាន់តែកើនឡើងឥតឈប់ឈរនៅទូទាំងពិភពលោកដោយពុំទាន់អាចកំណត់ពេលវេលាបិទបញ្ចប់បានឡើយ។ ព្រឹត្តិការណ៍នេះបានបណ្តាលឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កំណើនសេដ្ឋកិច្ច នៅតាមបណ្តាប្រទេសនីមួយៗ ក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ប្រជាជនបានធ្លាក់ចុះនូវប្រាក់ចំណូលដោយសារតែអាជីវកម្ម សេវាកម្មមួយភាគធំពុំអាចដំណើរការ បានលើកលែងតែបរកសិកម្មដែលនៅមានសកម្មភាពច្រើនគួរសម ។ ប្រឈមនឹងបញ្ហាវិបត្តសេដ្ឋកិច្ច និងសង្គមនេះ រាជរដ្ឋាភិបាលបានដាក់ចេញជាវិធានការទប់ស្កាត់ការរីករាលដាលនៃជម្ងឺកូវីដ១៩ បានយ៉ាងល្អប្រសើរ មិនឲ្យមានការចម្លងក្នុងសហគមន៍បានឡើយ ហើយដំណាក់កាលចុងក្រោយនេះ រាជរដ្ឋាភិបាលបានបញ្ចេញសាច់ប្រាក់ជាច្រើនដើម្បីជួយឧបត្ថម្ភគាំទ្រដល់ ប្រជាជនតាមរយៈការកំណត់អត្តសញ្ញាណប្រជាពលរដ្ឋក្រីក្រក្នុងកាលៈទេសៈដ៏លំបាកនេះ ។

ក្រសួងអភិវឌ្ឍន៍ជនបទក៏បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងនឹងជម្ងឺកូវីដ១៩ នេះ នៅតាមសហគមន៍ជនបទដោយបានធ្វើការផ្សព្វផ្សាយ អប់រំ ណែនាំពីវិធានអនាម័យប្រកបដោយប្រសិទ្ធភាពជូនដល់ប្រជាជនជនបទ ពិសេសការបញ្ឈប់បន្ទោរបង់ពាសវាលពាសកាល (ODF) នៅតាមភូមិ ឃុំ ស្រុក នៃតំបន់ជនបទកម្ពុជា ។ ការងារស្តាបនា ជួសជុលថែទាំផ្លូវ សាងសង់អណ្តូងទឹក ស្រះទឹក បង្គន់អនាម័យ នៅតែបន្តសកម្មភាពទៅតាមផែនការដែលបានកំណត់ ។

កិច្ចសហប្រតិបត្តិការជាមួយដៃគូអនុវត្តគម្រោងជាទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល នៅបន្តសហការប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

លទ្ធផលដែលក្រសួងសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០២០ នេះមានដូចខាងក្រោមៈ



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

## ២.វឌ្ឍនភាព

### ២.១. លទ្ធផលរួមរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

ការអនុវត្តផែនការសកម្មភាពក្នុងវិស័យអភិវឌ្ឍន៍ជនបទទាំងមូលសម្រេចបានប្រមាណជាង ៤០% នៃផែនការសកម្មភាពប្រចាំឆ្នាំ ២០២០ គិតត្រឹមឆមាសទី១ ឆ្នាំ២០២០ ។

### ២.២.លទ្ធផលរបស់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ

#### ២.២.១.ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០២០ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៥២២ នាក់ (ស្រី ៤០៩ នាក់)។ ក្រសួងបានទទួលលិខិតចូលចំនួន ៨១៧ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ៨២៧ ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ១២២ ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ១ ១៩៥ ច្បាប់ ។

#### ២.២.២.ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងឆមាសទី១ ក្រសួងបានអនុវត្ត ចំណាយចរន្តអនុវត្តបានចំនួន ១១ ៣០៥ ១១១ ៣៥៣ រៀល ស្មើនឹង ៧,៧៨% នៃច្បាប់ថវិកា ។ ចំណាយមូលធនអនុវត្តបានចំនួន ៤៤ ៧៧៦ ៣៩៦ ០០០ រៀល ស្មើនឹង ២៣,៥៧% នៃច្បាប់ថវិកា ។

#### ២.២.៣. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បន្តរៀបចំផែនការកែទម្រង់ហិរញ្ញវត្ថុសាធារណៈលម្អិតតាមខែនីមួយៗដើម្បីតាមដានការអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះ
- បញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ របស់ក្រសួងដោយបានបញ្ចូលគម្រោងវិនិយោគសាធារណៈបីឆ្នាំរំកិល គម្រោងវិនិយោគថវិការដ្ឋ គម្រោងវិនិយោគហិរញ្ញប្បទានដៃគូ បញ្ហាភាពក្រីក្រ និងយេនឌ័រចូលក្នុងផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល
- បន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពផែនការថវិកាឆ្នាំ ២០២១ របស់ក្រសួងដើម្បីត្រៀមលក្ខណៈចូលរួមចរចាកញ្ចប់ថវិកាប្រចាំឆ្នាំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍សមិទ្ធកម្មថវិកាកម្មវិធីប្រចាំឆមាសទី១ ឆ្នាំ២០២០
- ចូលរួមប្រជុំត្រួតពិនិត្យ និងវាយតម្លៃរបាយការណ៍អនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពប្រចាំខែ និងឆមាសក្នុងគេហទំព័រក្រសួង
- កំពុងដំណើរការអនុវត្តកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធ FMIS
- ចុះធ្វើសវនកម្មការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៩ នៅតាមមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានីខេត្ត
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៩ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ២.២.៤. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- ចូលរួមកិច្ចប្រជុំលើកទី ១៨ នៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ប្រារព្ធនៅទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ២.២.៥. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- រៀបចំសិក្ខាសាលាស្តីពីកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ឆ្នាំ២០២១-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធអនឡាញ
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការរៀបចំផែនការថវិកាកម្មវិធី ឆ្នាំ២០២១ ស្របតាមរចនាសម្ព័ន្ធផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ
- រៀបចំ និងសម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២១-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនាយកដ្ឋានជំនាញ និងមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្តទាំង ២៥
- រៀបចំ និងសម្របសម្រួលការរៀបចំផែនការថវិកាកម្មវិធីឆ្នាំ ២០២១ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនាយកដ្ឋានជំនាញ និងមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្តទាំង ២៥
- ចូលរួមកិច្ចប្រជុំក្រុមការងារតាក់តែងសមិទ្ធផល បញ្ជាប្រឈម ព័ត៌មាន ទិន្នន័យ វិធីសាស្ត្រយន្តការគណនា និងប្រើប្រាស់ធនធាន "កសពជ" នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចុះតាមដានការអនុវត្តថវិកាកម្មវិធីនៅខេត្តចំនួន ០៦ គឺ ខេត្តសៀមរាប កំពង់ធំ ស្ទឹងត្រែង បន្ទាយមានជ័យ ប៉ៃលិន និងខេត្តព្រះវិហារ
- ប្រមូលផែនការសកម្មភាពរបស់មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងបញ្ចូលទិន្នន័យក្នុងតារាងតាមដាន
- ពិនិត្យ និងប្រមូលរបាយការណ៍សមិទ្ធកម្ម ស្តីពីលទ្ធផលក្នុងការអនុវត្តថវិកាកម្មវិធីក្នុងឆមាសទី១ ឆ្នាំ២០២០
- បានផ្តល់លិខិតគាំទ្រកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងការបរទេស និងសហប្រតិបត្តិការ និងអង្គការមិនមែនរដ្ឋាភិបាល ជូនអង្គការចំនួន ០៦
- បានធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងគម្រោង រវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ០១ អង្គការ
- បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការ RDI
- បានផ្តល់លិខិតគាំទ្របន្តអនុស្សរណៈនៃការយោគយល់គ្នារវាងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជូនអង្គការចំនួន ០២
- បានផ្តល់លិខិតគាំទ្រសុំអន្តរាគមន៍ដើម្បីសុំចុះបញ្ជីស្លាកលេខ ONG សម្រាប់រថយន្ត និង

ទោចក្រយាន ជូនអង្គការចំនួន ០៤

- បានផ្តល់លិខិតគាំទ្ររបស់ក្រសួងអភិវឌ្ឍន៍ស្តីពីការទទួលជំនួយពីសប្បុរសជនក្នុង និងក្រៅប្រទេសរបស់សមាគមសម្របសម្រួល និងអភិវឌ្ឍន៍សង្គម
- ប្រមូលរបាយការណ៍ត្រីមាសទី១ និងឆមាសទី១ ឆ្នាំ២០២០ របស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆមាសទី១ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានចុះពិនិត្យការងារដាក់ស្តែងរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តកំពង់ធំ ក្រចេះ បន្ទាយមានជ័យ រតនគិរី មណ្ឌលគិរី និងខេត្តសៀមរាប
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ ។

### ២.២.៦. ការងារអធិការកិច្ច និងសវនកម្ម

- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៩-២០២០ និងចុះពិនិត្យដាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋនៅមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ចំនួន ១៥ រួមមាន រាជធានីភ្នំពេញ ខេត្តរតនគិរី មណ្ឌលគិរី កំពង់ស្ពឺ ក្រចេះ ស្ទឹងត្រែង កែប តាកែវ ខេត្តកំពត កណ្តាល ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ កំពង់ចាម និងខេត្តត្បូងឃ្មុំ
- ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងរដ្ឋបាល-ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋការិយបរិច្ឆេទ ២០១៩ នៅមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ចំនួន ០៩ រួមមាន រាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង កំពង់ធំ សៀមរាប បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ បន្ទាយមានជ័យ និងខេត្តកណ្តាល ។

### ២.២.៧. ការងារអភិវឌ្ឍន៍ផ្លូវជនបទ និងមន្ទីរពិសោធន៍

- គម្រោងថែទាំខួប ឆ្នាំ ២០២០ សរុបចំនួន ៣០ គម្រោង ស្មើនឹង ៥៧ ខ្សែ ប្រវែងសរុប ៤៦៣,៤២ គ.ម លូមូល ៦០ កន្លែង និងលូប្រអប់ ០២ កន្លែង សម្រេចលទ្ធផលគិតជាមធ្យមបាន ៥០%
- គម្រោងថែទាំប្រចាំ ឆ្នាំ ២០២០ សរុបចំនួន ៣៨ គម្រោង ស្មើនឹង ២៩៨ ខ្សែ ប្រវែងសរុប ២ ៨១៣,៧៤ គ.ម លូមូល ០១ កន្លែង និងស្លាកសញ្ញាចរាចរចំនួន ២ ១៥២ ស្លាក សម្រេចលទ្ធផលគិតជាមធ្យមបាន ៤០%
- ការងារស្តាបនា កែលម្អ និងជួសជុល ឆ្នាំ ២០២០ មាន ៩៧ គម្រោង ប្រវែងសរុប ៧២៤,៩១ គ.ម សម្រេចបានលទ្ធផលជាមធ្យម ៤១,៩៤%
- បានចុះសិក្សាបឋមផែនការឆ្នាំ ២០២១ បានចំនួន ០៦ គម្រោង
- បានបញ្ចប់ការងារពិសោធន៍សំណាកគំរូចំនួន ១៨ គម្រោងជាស្ថាពរ និងកំពុងបន្ត ធ្វើការពិសោធន៍សំណាកគំរូផ្សេងៗទៀត

- បាន និងកំពុងបណ្ដុះបណ្ដាលការងារតេស្ត DCP នៅការដ្ឋានជូនប្រធានផ្នែក និងមន្ត្រីបច្ចេកទេស ចំនួន ១៧ នាក់ ស្រី ០២នាក់
- បាន និងកំពុងបណ្ដុះបណ្ដាលការងារតេស្តកៅស៊ូ (Softening Point of Bitumen) ជូនប្រធានផ្នែក និងមន្ត្រីបច្ចេកទេសចំនួន ១៧ នាក់ ស្រី ០២ នាក់ ដើម្បីដឹងចំណាត់ថ្នាក់កៅស៊ូ និងទំនាក់ទំនងលំហូរកៅស៊ូទៅនឹងសីតុណ្ហភាព ។

**២.២.៨. ការងារផ្គត់ផ្គង់ទឹកជនបទ**

- ផលិតចម្រោះខ្សាច់ជីវសាស្ត្រ ផ្តល់ជូនប្រជាពលរដ្ឋនៅតាមភូមិគោលដៅបានចំនួន ៣៩១ ធុង មានអ្នកទទួលផលចំនួន ១ ៨៣៨ នាក់ ស្រី ៩៥២ នាក់ នៅស្រុកពោធិ៍រៀង និង ស្រុកពារាំង នៅខេត្តព្រៃវែង
- សាងសង់អណ្តូងអាហ្វ្រីដេវ និងអណ្តូងស្នប់ ចំនួន ១០ អណ្តូង នៅខេត្តក្រចេះ និងខេត្តប៉ៃលិន
- សាងសង់អាងត្រងទឹកភ្លៀងចំនួន ២៥ អាង នៅខេត្តប៉ៃលិន
- ជួសជុលអណ្តូងស្នប់ និងអណ្តូងអាហ្វ្រីដេវ ចំនួន ១១៤ អណ្តូង នៅខេត្តស្ទឹងត្រែង ក្រចេះ ព្រះសីហនុ មណ្ឌលគិរី ព្រះវិហារ និងខេត្តរតនគិរី ។

**២.២.៩. ការងារថែទាំសុខភាព និងអនាម័យជនបទ**

- ក្រុមការងារការគ្រប់គ្រងប្រព័ន្ធទិន្នន័យផ្គត់ផ្គង់ទឹកស្អាត និងសុខភាពអនាម័យជនបទ (MIS) បានរៀបចំសិក្ខាសាលាចំនួន ០២ លើក ដោយផ្តោតសំខាន់លើ ការពង្រឹងសមត្ថភាពការសរសេររបាយការណ៍គ្រប់គ្រងទិន្នន័យផ្គត់ផ្គង់ទឹកស្អាត ការសំអាត និងអនាម័យជនបទ
- ប្រជុំតាមប្រព័ន្ធអនឡាញ ស្តីពីការតាមដាន និងត្រួតពិនិត្យលើការរៀបចំប្រព័ន្ធឌីជីថលសម្រាប់ការគ្រប់គ្រងប្រព័ន្ធទិន្នន័យផ្គត់ផ្គង់ទឹកស្អាត និងសុខភាពអនាម័យជនបទ
- បានចុះសិក្សា និងជ្រើសរើសទីតាំងដាក់បង្គន់អនាម័យជនបទ ឆ្នាំ ២០២០ នៅតាមភូមិគោលដៅចំនួន ១៥៧ ភូមិ ក្នុងខេត្តគោលដៅទាំង ១៣ រួមមាន ខេត្តក្រចេះ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ ត្បូងឃ្មុំ ប៉ៃលិន ព្រះសីហនុ សៀមរាប កោះកុង កែប ឧត្តរមានជ័យ ព្រះវិហារ និងខេត្តស្វាយរៀង
- បានចុះអប់រំប្រជាពលរដ្ឋ អោយយល់ដឹងពីការប្រើប្រាស់បង្គន់អនាម័យ និងការប្រតិបត្តិអនាម័យល្អនៅតាមគ្រួសារ ក្នុងខេត្តគោលដៅទាំង ១៣ រួមមានខេត្តកោះកុង កែប ព្រះសីហនុ កំពង់ស្ពឺ កំពង់ឆ្នាំង ប៉ៃលិន សៀមរាប ឧត្តរមានជ័យ ក្រចេះ កំពង់ចាម ត្បូងឃ្មុំ ព្រះវិហារ និងខេត្តស្វាយរៀង
- បានចុះអប់រំ និងផ្សព្វផ្សាយការលើកកម្ពស់អនាម័យសហគមន៍ចំនួន ១០ សហគមន៍នៅសង្កាត់ទួលសង្កែ និងសង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ ។ ការងារទាំងនោះផ្តោតសំខាន់លើការចែកកន្ទោអនាម័យកុមារ សាប៊ូ និងការអប់រំផ្សព្វផ្សាយពីវិធានការការពារជម្ងឺកូវីដ១៩ ដោយមានអ្នកចូលរួមសរុប ៣០០ នាក់
- បានចុះចែក Poster COVID-19, Poster Hand Washing, សាប៊ូដុំសម្រាប់លាង

សម្អាតដៃចំនួន ០១ លើកនៅសង្កាត់ចំនួន ០២ និងសហគមន៍ចំនួន ០១ គឺសង្កាត់ស្វាយប៉ាក និងសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ និងសហគមន៍ផ្សារតូច

- បានចុះពិនិត្យផ្ទៀងផ្ទាត់ភូមិ ODF ដោយសហការជាមួយ អង្គការ Plan International Cambodia និងអង្គការ SNV ចំនួន ០៣ លើក ។ ដោយមកដល់បច្ចុប្បន្នភូមិ ODF មានចំនួន ២ ៧៣៩ ភូមិ ឃុំ ODF ចំនួន ១២៥ ឃុំ និងស្រុក ODF ចំនួន ០៥ ស្រុក
- បានចូលរួមផ្សព្វផ្សាយការកាត់បន្ថយហានិភ័យពីការឆ្លងជំងឺកូវីដ១៩ នៅខេត្តតាកែវ កំពង់ស្ពឺ និងខេត្តស្វាយរៀង ដោយផ្តោតលើការងារចែកសាប៊ូដល់គ្រួសារក្រីក្រ បញ្ចូលសារអប់រំអនាម័យ និងការការពារជំងឺឆ្លង
- បានរៀបចំក្រុមការងារដើម្បីពិនិត្យផ្ទៀងផ្ទាត់ បង្គន់សង់ថ្មីចំនួន ៧៥ បង្គន់ នៅខេត្តកំពង់ស្ពឺ ដែលមានអ្នកចូលរួមពីរដ្ឋបាលស្រុកសំរោងទង ឱរ៉ាល់ ឧដុង្គ និងស្រុកគងពិសី ។

**២.២.១០. ការងារអភិវឌ្ឍន៍សហគមន៍**

- ចុះធ្វើបច្ចុប្បន្នភាព និងរៀបចំផែនការសកម្មភាពបណ្តុះបណ្តាល គ.អ.ភ នៅខេត្តបន្ទាយមានជ័យ សៀមរាប ស្វាយរៀង កណ្តាល កំពង់ធំ ត្បូងឃ្មុំ កំពង់ស្ពឺ កំពង់ឆ្នាំង តាកែវ កំពត និងខេត្តព្រៃវែង
- ចុះតាមដានដានសកម្មភាពបណ្តុះបណ្តាល គ.អ.ភ រៀបចំដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ត្បូងឃ្មុំ កំពង់ស្ពឺ កំពង់ឆ្នាំង តាកែវ និងខេត្តព្រៃវែង
- ចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ នៅខេត្តព្រះសីហនុ
- ចុះពិនិត្យវគ្គបណ្តុះបណ្តាលស្តីពីសួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្តដល់គ្រួសារសហគមន៍ នៅខេត្តកែប និងខេត្តសៀមរាប
- រៀបចំមេរៀនសម្រាប់ការអប់រំក្រៅប្រព័ន្ធ
- រៀបចំរបាយការណ៍សមិទ្ធកម្មក្នុងឆមាសទី ១ ឆ្នាំ២០២០
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ និងខេត្តកំពង់ស្ពឺ បានបន្តធ្វើការផ្សព្វផ្សាយជ្រើសរើសសិស្សឲ្យចូលរៀនវគ្គបណ្តុះបណ្តាល ឆ្នាំ២០២០ ។

**២.២.១១. ការងារបណ្តុះបណ្តាល**

- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ១៣៦ នាក់ ស្រី ១៤ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ០៤ នាក់ ស្រី ០១ នាក់
- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ៣៧៥ នាក់ ស្រី ៣៨ នាក់
- បានផ្សព្វផ្សាយសេចក្តីជូនដំណឹងដល់មន្ត្រីរាជការរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ទាក់ទងនឹងអាហារូបករណ៍ និងព័ត៌មានផ្សេងៗ ចំនួន ១៧ លើក
- បានរៀបចំឯកសារបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសបានចំនួន ១៨ លើក

- បានរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ចំនួន ០២ លើក នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ និងភោជនីយដ្ឋានទន្លេបាសាក់II ដោយមានសិក្ខាកាមចូលរួមសរុប ១៤៣ នាក់ ស្រី ១៦ នាក់
- បានរៀបចំចងក្រងបញ្ជីសំនួរស្តីពីតម្រូវការរបស់ការិយាល័យបណ្តុះបណ្តាល នៅតាមមន្ទីរអភិវឌ្ឍន៍ជនបទទាំង២៥ រាជធានី-ខេត្ត
- បានរៀបចំគម្រោងមេរៀន ស្តីពីតួនាទី និងភារកិច្ចរបស់ជនបង្គោលការិយាល័យបណ្តុះបណ្តាលនៅតាមអង្គភាពក្រោមឱវាទក្រសួង
- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ១៣ ខេត្ត បានបើកវគ្គបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី ប៉ុន្តែត្រូវធ្វើការផ្អាកជាបណ្តោះអាសន្ន ដោយសារបញ្ហាជំងឺកូវីដ១៩ ។

## ២.២.១២. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០២០ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់បានផ្តល់ឥណទានសរុបចំនួន ៤ ២១១ ៣១៧ ៩៣៥ រៀល (បួនប៊ីលានពីររយដប់មួយលានបីរយដប់ប្រាំពីរពាន់ប្រាំបួនរយសាមសិបប្រាំរៀល) ស្មើនឹង ១ ០៧២ ០៥៥ ,៤៤ ដុល្លារអាមេរិក (មួយលានចិតសិបពីរពាន់ហាសិបប្រាំដុល្លារ និងសែសិបបួនសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ១៦៧ នាក់ នៅភូមិគោលដៅចំនួន ១៩១ ភូមិ ៧៤ ឃុំ ៣៣ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥
- បានចុះពិនិត្យមើលស្ថានភាពផ្សារជនបទ ដើម្បីសិក្សាលទ្ធភាពធ្វើការកែលម្អ
- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ផ្លាស់ប្តូរបទពិសោធន៍ជោគជ័យ និងបញ្ហាប្រឈមរបស់ទីផ្សារផលិតផលជនបទ នៅខេត្តកំពង់ចាម
- បានរៀបចំសិក្ខាសាលាស្វែងយល់ពីទីផ្សាររបស់ផលិតផលជនបទ នៅខេត្តពោធិ៍សាត់
- បានចុះត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពក្រោយពីវគ្គបណ្តុះបណ្តាលបច្ចេកទេសផលិតសាប៊ូ នៅខេត្តសៀមរាប កំពង់ឆ្នាំង កំពង់ធំ និងខេត្តបាត់ដំបង
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីគំនិតផ្តួចផ្តើម និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច នៅខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម ។

## ២.២.១៣. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- ចូលរួមប្រជុំជាមួយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) ពាក់ព័ន្ធទៅនឹងការផ្តល់ធាតុចូលបន្ថែមទៅលើសេចក្តីព្រាង នៃផែនការយុទ្ធសាស្ត្រ អភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច ដោយពិនិត្យទៅលើទម្រង់ និងសកម្មភាពសំខាន់ៗ នៃផែនការយុទ្ធសាស្ត្រ អភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច
- ប្រជុំជាមួយអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO) ពាក់ព័ន្ធនឹងការកែសម្រួលបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិច ។

### ២.២.១៤.ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

ក្នុងឆមាសទី១ ឆ្នាំ ២០២០ នេះ លេខាធិការដ្ឋានក្រុមការងារចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានចំនួន ៤២ ករណី និងបានដោះស្រាយជូនប្រជាពលរដ្ឋចំនួន ១៣ ករណី ។

### ២.២.១៥. ការងារយេនឌ័រ

- ចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការតាមដាន និងវាយតម្លៃការអនុវត្តអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(ស៊ី-ដ)
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសមត្ថភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ ២០១៩-២០២៣
- ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីផលប៉ះពាល់នៃកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ ។

### ២.២.១៦. ការងារប្រយុទ្ធនឹងជំងឺអេដស៍

- ប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០២០ ។

## ២.៣. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការទ្វេភាគី និងពហុភាគី

### ២.៣.១. គម្រោងកែលម្អផ្លូវជនបទ ជំហាន ២

គិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ ២០២០ នេះ គម្រោងសម្រេច៖

- បានបញ្ចប់ការសាងសង់ផ្លូវ នៅខេត្តត្បូងឃ្មុំ កំពង់ចាម ពោធិ៍សាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ ដែលមានប្រវែងសរុប ៥៦១,៣០ គ.ម
- បានបញ្ចប់ការសាងសង់ប្រឡាយទឹកស្រោចស្រពដំណាំ និងមណ្ឌលសុខភាព នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១០៤,០៨ គ.ម សម្រេចបាន ៧៧,៤២%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៧៨,៩៦%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១២៦,៣០ គ.ម សម្រេចបាន ៧២,៦៦%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៨៤,៦៣%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ ខ្សែ ប្រវែង ១១៣,៤០ គ.ម សម្រេចបាន ៩១,២១% ។

### ២.៣.២. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ

គម្រោងបាន និងកំពុងអនុវត្តចំនួន ៦៥ អនុគម្រោង ប្រវែង ១៧៣ ៨២៤ ម៉ែត្រ ក្នុងខេត្តគោលដៅចំនួន ១២ ក្នុងនោះបានបញ្ចប់ការងារ បានចំនួន ៦០ អនុគម្រោង ប្រវែងសរុប ១៦៨ ៧៥៤

ម៉ែត្រ ក្នុងខេត្តគោលដៅទាំង ១២ ។

**២.៣.៣.គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង (Mekong Lancang Cooperation)**

- ចុះត្រួតពិនិត្យមើលសមិទ្ធផលនៃគម្រោងជំហានទី១ ការងារសាងសង់បង្គន់អនាម័យ ចំនួន ២៨ បង្គន់ ចង្ក្រានបច្ចេកទេសដុតអុសចំនួន ២០ ចង្ក្រាន និងស្លាកសញ្ញាផ្សព្វផ្សាយអនាម័យ និងបរិស្ថានចំនួន ៨០ ស្លាក
- ត្រួតពិនិត្យការអនុវត្តបច្ចេកទេសផលិតសាប៊ូតាមគ្រួសារដែលបានបណ្តុះបណ្តាលរួច នៅខេត្តគោលដៅចំនួន០៤ គឺ ខេត្តក្រចេះ ស្ទឹងត្រែង ព្រៃវែង និងខេត្តកណ្តាល
- ចុះត្រួតពិនិត្យការងារសាងសង់ផ្សារជនបទ ពិនិត្យទីតាំង និងបញ្ហាប្រឈម
- ប្រជុំពិភាក្សាជាមួយអាជ្ញាធរ ០៤ ស្រុក នៃខេត្តកំពង់ឆ្នាំងលើនីតិវិធីគ្រប់គ្រងរដ្ឋបាលផ្សារជនបទដែលកំពុងសាងសង់
- រៀបចំ និងបង្កើតផែនការសកម្មភាពសហគមអាជីវកម្មចំនួន ០៥ កន្លែង
- រៀបចំរបាយការណ៍ និងឯកសារទូទាត់ថវិកាជំហានទី១ ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំគម្រោងសំណើថ្មីបន្ថែមទៀតទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**២.៣.៤. គម្រោងសហប្រតិបត្តិការមេគង្គ-គង្គា**

- សិក្សាទិន្នន័យអាសេនិកនៅខេត្តគោលដៅចំនួន ០៤ គឺខេត្តពោធិ៍សាត់ កំពង់ឆ្នាំង បាត់ដំបង និងខេត្តសៀមរាប
- ប្រជុំបច្ចេកទេសត្រួតពិនិត្យតំបន់ដែលមានជាតិអាសេនិកក្នុងទឹក
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយសុខភាព ទឹកស្អាត អនាម័យ នៅឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ចំនួន ០២ លើក
- បណ្តុះបណ្តាលបច្ចេកទេសផលិតសាប៊ូនៅខេត្តព្រៃវែង ចំនួន ០១ វគ្គ មានអ្នកចូលរួម ៦៥ នាក់
- សាងសង់បង្គន់អនាម័យបានចំនួន ២០ នៅភូមិថ្មីខ្មែរ និងភូមិវាលតាគីង ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
- បានរៀបចំរបាយការណ៍ជំហានទី១ ។

**២.៣.៥. គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍**

ក្នុងឆមាសទី ១ ឆ្នាំ ២០២០នេះ គម្រោងសម្រេច៖

- បាន និងកំពុងសាងសង់ផ្លូវ ចំនួន ០៧ ខ្សែ ប្រវែង ៤៩,៨៩គីឡូម៉ែត្រ នៅខេត្តកណ្តាល ដោយសម្រេចបាន ៦%
- បាន និងកំពុងធ្វើការវាយតម្លៃឯកសារដេញថ្លៃ កញ្ចប់ទី២ សម្រាប់ការស្តារបនាផ្លូវប្រវែង ៤៥ គីឡូម៉ែត្រ នៅក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដែលជាប្រភេទផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) និងបេតុង
- បាន និងកំពុងធ្វើការវាយតម្លៃឯកសារដេញថ្លៃកញ្ចប់ទី៣ សម្រាប់ការស្តារបនាផ្លូវប្រវែង

១៦០ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ០៣ រួមមាន ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប ជាប្រភេទផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) និងបេតុង

- បាន និងកំពុងរៀបចំឯកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការងារ Road Asset Inventory System
- បានចុះកិច្ចសន្យាជាមួយទីប្រឹក្សា Senior Road Engineer Advisor ។

**២.៣.៦. គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ជំហាន ២**

គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទ ជំហាន២ អនុវត្តរយៈពេល ១២ខែ ក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលក្នុងនោះគម្រោងផ្គត់ផ្គង់ទឹកជនបទអនុវត្តនៅខេត្តគោលដៅចំនួន ១០ គឺខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង ព្រៃវែង កំពត ស្វាយរៀង កំពង់ស្ពឺ និងខេត្តកំពង់ចាម និងគម្រោងកែលម្អផ្លូវជនបទ ជំហាន ២ អនុវត្តនៅខេត្តគោលដៅចំនួន ០៦ រួមមាន ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង កណ្តាល ព្រៃវែង ស្វាយរៀង និងខេត្តត្បូងឃ្មុំ ។ នៅក្នុងឆមាសទី១ ឆ្នាំ ២០២០ គម្រោងសម្រេចបាន៖

- ជីកអណ្តូងបានចំនួន ៦៤៤ អណ្តូង
- តំឡើងស្នប់បានចំនួន ៣៤៣ ស្នប់
- ជីកស្រះធម្មតា និងស្រះមានរៀបថ្ម ចំនួន ២៤ ស្រះ
- បាន និងកំពុងសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ១១៩,៥៥ គ.ម នៅខេត្តគោលដៅទាំង ០៦ សម្រេចបាន ២២ % ។

**២.៣.៧. គម្រោងពិពិធកម្មកសិកម្មកម្ពុជា**

គម្រោងពិពិធកម្មកសិកម្មកម្ពុជាអនុវត្តរយៈពេល ០៦ឆ្នាំ គិតចាប់ពី ឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៤ ។ គម្រោងមានគោលបំណង ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍខ្សែច្រវ៉ាក់ផលិតផលកសិកម្មចម្រុះ នៅក្នុងតំបន់ភូមិសាស្ត្រ នៅខេត្តគោលដៅចំនួន ១៣ រួមមាន ខេត្តត្បូងឃ្មុំ កណ្តាល បាត់ដំបង កំពង់ចាម កំពង់ស្ពឺ សៀមរាប ព្រះវិហារ មណ្ឌលគិរី ស្ទឹងត្រែង រតនគិរី ក្រចេះ កំពង់ឆ្នាំង និងរាជធានីភ្នំពេញ ។ នៅក្នុងឆមាសទី១ ឆ្នាំ ២០២០ នេះគម្រោងសម្រេចបាន ៖

- កំពុងដំណើរការជ្រើសរើសក្រុមទីប្រឹក្សាបច្ចេកទេស (ជ្រើសរើសទីប្រឹក្សាបច្ចេកទេសផ្នែកលទ្ធកម្ម និងហិរញ្ញវត្ថុ)
- បានទទួលការអនុម័តលើផែនការថវិកា និងសកម្មភាពប្រចាំឆ្នាំ ២០១៩ និង ឆ្នាំ ២០២០ សម្រាប់ការអនុវត្តគម្រោង ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានបង្កើតគណៈកម្មាធិការត្រួតពិនិត្យលទ្ធកម្ម (PRC) និងគណៈកម្មាធិការវាយតម្លៃទីប្រឹក្សា និងគណៈកម្មាធិការវាយតម្លៃការដេញថ្លៃ(BEC) ។

**២.៣.៨. គម្រោងសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល**

សកម្មភាពអង្គការមិនមែនរដ្ឋាភិបាលចូលរួមអភិវឌ្ឍន៍ក្នុងសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល

(NGOs) ចំនួន ៤៥ បានសហការជាមួយក្រសួងដោយ ចូលរួមចំណែកក្នុងការអភិវឌ្ឍសហគមន៍ រួមចំណែកកែលម្អលក្ខខណ្ឌរស់នៅ និងលើកកម្ពស់ជីវភាព របស់សហគមន៍ជនបទនៅក្នុងកម្មវិធីទី២ លទ្ធផលដែលអង្គការសម្រេចបាន ក្នុងឆមាសទី១ មានដូចខាងក្រោម៖

- **ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៖** សាលារៀន ០៣ ខ្នង ព្រះវិហារ ០១ ខ្នង មណ្ឌលសុខភាព ០៦ ខ្នង សាលាមតេយ្យសហគមន៍បាន ១៩ ខ្នង ផ្លូវជនបទក្រាលក្រួសក្រហមបាន ០៥ ខ្សែ ជួសជុលផ្លូវជនបទ ០១ ខ្សែ ជួសជុលស្ពាន ០៤ កន្លែង សាងសង់ផ្ទះជូនប្រជាពលរដ្ឋ ១៦ ខ្នង និងជួយជួសជុលផ្ទះជូនប្រជាពលរដ្ឋបាន ០១ ខ្នង ។ ជីកស្រះសហគមន៍ ៤៥ ស្រះ សាងសង់បង្គន់អនាម័យគ្រួសារ ២៣ ៩៦៨ បង្គន់ ជួសជុលបង្គន់ និងផ្តល់សម្ភារបង្គន់ ៥៨៤ គ្រួសារ សាងសងប្រឡាយទឹក ០៧ ខ្សែ និងទំនប់ទឹក ០៨ ខ្សែ សាងសង់អាងត្រងទឹកភ្លៀង ១៥ អាង សាងសង់ស្ថានីយ៍ទឹកស្អាតបាន ០៥ កន្លែង រៀបចំកន្លែងលាងសម្អាតដៃចំនួន ៧ ២៦៧ កន្លែង តម្លើងប្រព័ន្ធចែកចាយទឹកតាមភូមិ ៦៥០កន្លែង ចែកធុងទឹក ៩ ៧៦៨ធុង ធុងសម្រាម ១៥៨ ធុង សាងសង់ឡដុតសម្រាម ៥៦កន្លែង តម្លើង បាណ្ឌផ្សព្វផ្សាយអនាម័យបាន ១៩ កន្លែង
- **ចែកជូនសម្ភារកសិកម្ម** ៖ ចែកគោយន្ត ១៨ គ្រឿង ទូកឈើ ០២គ្រឿង សាងសង់រោងកែច្នៃសាច់បាន ០១ខ្នង សាងសង់ Green house ០៦ កន្លែង បង្កើតសួនបន្លែបាន ៩៨កន្លែង ផ្តល់ម៉ាស៊ីនបោកស្រូវចំនួន ០៣គ្រឿង ម៉ាស៊ីនបូមទឹក ៦៣ គ្រឿង ផ្តល់គោយន្ត ៨០ គ្រឿង មាន់ពូជ ២ ៦៣២ ក្បាល ចែកពូជដំណាំហូបផ្លែ ១ ២៩៧ ដើម
- បើកវគ្គបណ្តុះបណ្តាលផ្សេងៗបាន ១ ៧២៦ វគ្គ ។

## ៣. ទិសដៅបន្ត

### ៣.១. បញ្ហាប្រឈម

- ពន្យាពេលរៀបចំសិក្ខាសាលាបូកសរុបផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ និងថវិកាកម្មវិធី ដោយសារបញ្ហាជម្ងឺកូវីដ១៩
- គម្រោងសាងសង់មួយចំនួនមិនអាចបញ្ចប់តាមការគ្រោងទុកដោយសារបញ្ហាជម្ងឺកូវីដ១៩
- ការផ្លាស់ប្តូរទម្លាប់របស់ប្រជាជនក្នុងការប្រតិបត្តិអនាម័យល្អ ត្រូវការពេលវេលា
- សមត្ថភាពចូលរួមផ្តល់សេវារបស់វិស័យឯកជននៅមានកម្រិត
- តំបន់ខ្លះខ្វះទឹកដែលអាចប៉ះពាល់ដល់ស្ថានភាពអនាម័យ
- ទម្លាប់សង្គមក្នុងការបន្ទោរបង់ពាសវាលពាសកាល មិនទម្លាប់ផឹកទឹកស្អាត និងការលាងដៃឲ្យបានត្រឹមត្រូវ ខ្វះការយល់ដឹង ដែលនាំឲ្យកម្រិតវិនិយោគពីគ្រួសារទាប
- ទីផ្សារអនាម័យនៅមានកម្រិត (បច្ចេកវិទ្យា ផលិតផល ការផ្គត់ផ្គង់បរិក្ខារអនាម័យ)
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- ប្រជាពលរដ្ឋនៅតាមមូលដ្ឋានមួយចំនួនមានជីវភាពខ្វះខាត ជាហេតុនាំឲ្យមានការធ្វើចំណាកស្រុកទៅប្រកបមុខរបរនៅប្រទេសជិតខាង ដែលធ្វើឲ្យប៉ះពាល់ដល់ដំណើរការនៃការអនុវត្តសកម្មភាពអភិវឌ្ឍន៍នៅមូលដ្ឋានរបស់ខ្លួន

- គ.អ.ភ ពុំមានស្នាក់ការសម្រាប់ធ្វើការងារ
- ស្ថាប័ន ឬអង្គការមួយចំនួន មិនបានប្រើប្រាស់ គ.អ.ភ ហើយបានបង្កើតជនបង្គោលផ្សេងៗពី គ.អ.ភ
- កិច្ចសហការជាមួយអង្គការ ដៃគូអភិវឌ្ឍន៍ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត នៅមានកម្រិតនៅឡើយលើវិស័យឥណទានជនបទ និងសកម្មភាពបង្កើនប្រាក់ចំណូលផ្សេងៗ ។

**៣.២. ទិសដៅតាមអង្គភាព**

- គ្រោងរៀបចំសិក្ខាសាលាបូកសរុបលទ្ធផលនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ និងថវិកាកម្មវិធីឆ្នាំ ២០២១ នៅទីស្តីការក្រសួង
- ត្រៀមលក្ខណៈ និងឯកសារចូលរួមការចរចាកញ្ចប់ថវិកាឆ្នាំ២០២១ នៅខែកក្កដា
- បន្តចុះតាមដានការអនុវត្តផែនការឆ្នាំ ២០២០ តាមអង្គភាពថវិកា
- ចុះតាមដានសកម្មភាពអង្គការមិនមែនរដ្ឋាភិបាល
- បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូ និងអង្គការមិនមែនរដ្ឋាភិបាល
- បន្តចុះធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តជំរុញការងារតាមការដ្ឋានសាងសង់ផ្លូវ ដើម្បីបញ្ចប់ការងារឲ្យបានទាន់ពេលវេលា
- បន្តចុះត្រួតពិនិត្យការងារស្ថាបនា និងកែលម្អផ្លូវជនបទ
- អនុវត្តការងារថែទាំ និងជួសជុលផ្លូវនៅតាមបណ្តាខេត្ត
- បន្តការងាររៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ ទូទាំង ២៥ រាជធានី ខេត្ត
- ផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បន្តការរៀបចំផែនការនិងកិច្ចសហការនានាជាមួយអង្គការដៃគូនានាលើកម្មវិធីលើកកម្ពស់អនាម័យជនបទ
- បន្តសហការសាកល្បងការផ្ទេរមុខងារអនាម័យទៅរដ្ឋបាលថ្នាក់ស្រុកទាំង ១៥ ក្នុងខេត្តគោលដៅទាំង ០៣ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- សិក្សាស្រុកគោលដៅថ្មី និងរៀបចំឯកសារគតិយុត្តសម្រាប់ស្រុកចំនួន ១៥ ដែលត្រូវសាកល្បងផ្ទេរមុខងារអនាម័យ
- ត្រៀមរៀបចំពិនិត្យសារឡើងវិញនូវផែនការសកម្មភាពជាតិជំហានទី១ (២០១៤-២០១៨) និងរៀបចំធ្វើផែនការសកម្មភាពជាតិជំហានទី២ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់ អនាម័យជនបទ (២០១៩-២០២៣)
- រៀបចំឯកសារគោលការណែនាំ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដែលបានសហការជាមួយអង្គការ Water Aid សម្រាប់គាំទ្រដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះ
- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដើម្បីលើកកម្ពស់

សមត្ថភាពមន្ត្រី

- បន្តជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឲ្យបង្កើតសហគ្រាសខ្នាតគ្រួសារ និងខ្នាតតូច
- ពង្រឹងការផ្តល់សេវាជូនប្រជាពលរដ្ឋដូចជាការងារឥណទានសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ ការបណ្តុះបណ្តាលបំនិនជីវិត ការរកទីផ្សារសម្រាប់ផលិតផលជនបទជាដើម
- សិក្សាភូមិគោលដៅដើម្បីរៀបចំកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- បន្តការចុះកំណត់អត្តសញ្ញាណ បទបញ្ញាផ្ទៃក្នុង និងលក្ខន្តិកៈរបស់ក្រុមជនជាតិដើមភាគតិច ។

## ៤.សេចក្តីសន្និដ្ឋាន

លទ្ធផលសម្រេចជារួមក្នុងឆមាសទី១ ឆ្នាំ២០២០ ក្រសួងសម្រេចបានជាង ៤០% នៃផែនការ ដោយសារជម្ងឺកូវីដ១៩ បានបង្កឲ្យរាំងស្ទះសកម្មភាពការងារមួយចំនួនរបស់ក្រសួង ។ ទោះបីជាយ៉ាងនេះក៏ដោយក៏ក្រសួងនៅតែអាចបន្តសកម្មភាពបានខ្លះៗដោយត្រូវអនុវត្តតាមវិធាននានារបស់ក្រសួងសុខាភិបាលដើម្បីបញ្ចៀសការឆ្លងជម្ងឺកូវីដ១៩ ។ ក្រសួងកំពុងរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទរយៈពេល ១០ ឆ្នាំដោយគិតពីឆ្នាំ២០២១-២០៣០ ដោយមានការចូលរួមពិភាក្សា និងផ្តល់យោបល់ពីគ្រប់អង្គភាពជំនាញ និងថ្នាក់ដឹកនាំក្រសួង ដើម្បីសម្រួច និងតម្រង់ទិសការអភិវឌ្ឍជនបទឆ្ពោះទៅរកវឌ្ឍនភាព និងសុខដុមនីយកម្មក្នុងសង្គមគ្រួសារនៅជនបទនៃប្រទេសកម្ពុជានៅពេលអនាគត ៕

**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**